ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សធាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២០៣
ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩
សាលដីកា
លេខ ០៤ "แ"
ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

# សាលដីកា
## តាមនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកស្រី [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោក [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមាន ៖

- ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា ភេទប្រុស អាយុ២២ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងកាត់កញ្ចក់ មានទីកន្លែងកំណើតនៅភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅមុនពេលចាប់ខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន។ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម១) នៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ។ (អ្នកប្តឹងសុំស្រូបទោស)



Scanned with CamScanner

- ឧទ្ទេសកុំ ប្ដឹងសុំស្រូបទោសបញ្ចូលគ្នា ។

## អំពីមូលហេតុនៃបណ្ដឹង

តាមពាក្យសុំឱ្យស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា បានលើកឡើងថា ខ្លួនមានសំណុំរឿងព្រហ្មទណ្ឌចំនួន០២ ករណីដែលមានសាលដីកាបានចូលជាស្ថាពរទាំងពីររួចហើយ។

សំណុំរឿងទី១

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៤៩៦ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

-សាលក្រមលេខ ៨៨ "ម" ក្រ៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន ០៦ឆ្នាំ (ប្រាំមួយឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោស (ប្រើអាវុធខ្លីក្ដង់ជនរងគ្រោះ) ប្រព្រឹត្តនៅចំណុចមុខសាលាបឋមសិក្សាពញាក្រែក ផ្លូវលេខ៩៣ ក្រុមទី១៩ភូមិទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥។

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧៩៨ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍។

-សាលដីកាស្ថាពរលេខ ៣១ ក្រVI "ប.ស" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ បានសម្រេចតម្កល់សាលក្រមលេខ ៨៨ "ម" ក្រ៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

សំណុំរឿងទី២

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៤៨១ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

-សាលក្រមលេខ ៤៧២ "ក្រ១ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ចំនួន ០៦ឆ្នាំ (ប្រាំមួយឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោស (ប្រើអាវុធខ្លីក្ដង់ជនរងគ្រោះ) ប្រព្រឹត្តនៅចំណុចមុខសាលបឋមសិក្សាពញាក្រែកផ្លូវលេខ ៩៣ ក្រុមទី១៩ ភូមិទួលសង្កែ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៥។

-សំណុំរឿងព្រហ្មទណ្ឌលេខ ១៣៣៧ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ របស់សាលាឧទ្ធរណ៍។

-សាលដីកាស្ថាពរលេខ ២៣ ក្រV "រ" ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ បានសម្រេចតម្កល់សាលក្រមលេខ ៤៧២ "ក្រ១ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

ដោយឆ្លងកាត់តាមការអប់រំ ក្នុងមណ្ឌលអប់រំកែប្រែទី១ នាពេលកន្លងមកខ្លួនបានដឹងពីកំហុសរបស់ខ្លួន បានគោរពប្រតិបត្តិយ៉ាងហ្មត់ចត់ ត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់មណ្ឌល និងបានយកចិត្ត



Scanned with CamScanner

ទុកដាក់បំពេញការងារពលកម្ម យ៉ាងសកម្មទៀងទាត់ដែលជាគំរូដល់ទណ្ឌិតដទៃទៀត។ ខ្លួនមានស្មារតីភ្ញាក់រលឹក ខិតខំលត់ដំកែប្រែខ្លួនបានល្អ និងបានប្តេជ្ញាចិត្ត ខិតខំរៀនសូត្រអប់រំខ្លួនឱ្យក្លាយជាពលរដ្ឋសុចរិតមានប្រយោជន៍ដល់សង្គមជាតិ។

សំណូមពរ ខ្លួនស្នើសុំអនុវត្តឱ្យស្រូបទោសបញ្ចូលគ្នា ដោយសុំឱ្យសាលក្រមលេខ ៨៨ "ម" ក្រ៦ ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាស្ថាពរលេខ ៣១ ក្រVI "ប.ស" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ និងសាលក្រមលេខ ៤៧២ "ក្រ១ន" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ និងសាលដីកាស្ថាពរលេខ ២៣ ក្រV "រ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ស្រូបទោសបញ្ចូលគ្នាទាំងមូល។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តមប្រធាន មេត្តាពិនិត្យ និងលើកយកសាលក្រម និងសាលដីកាស្ថាពរទាំង០២ នេះមកធ្វើការជំនុំជម្រះ ដោយស្រូបទោសបញ្ចូលគ្នា ដល់ខ្លួនដោយក្តីអនុគ្រោះ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅះ

១.ទទួលពាក្យសុំស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២.ស្រូបទោសក្នុងសាលដីកាស្ថាពរលេខ ២៣ ក្រV (រ) ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ចំនួន០២ (ពីរ)ឆ្នាំ បញ្ចូលមកក្នុងសាលដីកាស្ថាពរលេខ ៣១ ក្រVI "ប.ស" ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដូច្នេះទោសដែលត្រូវអនុវត្តគឺ ចំនួន១០ (ដប់) ឆ្នាំ។

៣.សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញ បណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា ប្តឹងមិនសុខចិត្តទៅនឹងសាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា ទណ្ឌិតឈ្មោះ [redacted] វិច្ឆិកា បានប្តឹងសុំស្រូបទោសបញ្ចូលគ្នា លើសាលក្រមស្ថាពរចំនួន ២ ដែលមានទណ្ឌកម្ម សរុបមានចំនួន ១២ឆ្នាំ ហើយសាលាឧទ្ធរណ៍បានសម្រេចស្រូបទោសមកត្រឹម១០ឆ្នាំ ឃើញថាការសម្រេចនេះមានលក្ខណៈត្រឹម

Scanned with CamScanner

ត្រូវហើយ ព្រោះថាបើយោងតាមមាត្រា ១៣៨ នៃក្រមព្រហ្មទណ្ឌ បានកំណត់ថា ទោសដែលត្រូវប្រកាសអនុវត្តគ្រូតគ្នា នៅក្នុងព្រំដែននៃអតិបរិមាស្របច្បាប់ខ្ពស់ជាងគេ។ ហើយការផ្តន្ទាទោសលើទណ្ឌិតពីបទលួចមានស្ថានទម្ងន់ទោស ហេតុនេះ ទណ្ឌកម្មខ្ពស់ជាងគេគឺ ១០ឆ្នាំ ឃើញថាមានលក្ខណៈត្រឹមត្រូវហើយ។ តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-លោកមេធាវី [redacted] ផានិត បានធ្វើសេចក្តីសន្និដ្ឋានការពារទណ្ឌិត [redacted] វិច្ឆិកា ថា យើងឃើញហើយថាបទល្មើសរបស់គាត់ គឺបទល្មើសដូចគ្នា ហើយនៅក្នុងអំឡុងឆ្នាំតែមួយ។ បើគិតពីការព្យសនកម្មវិញ គឺមានព្យសនកម្មតិចតួចទៅនឹងទំហំនៃការប្រព្រឹត្ត។ ទាក់ទងទៅនឹងការស្រូបទោស គឺ ដើម្បីស្រូបទោសឱ្យមានភាពយុត្តិធម៌សម្រាប់អ្នកសុំ យល់ឃើញថាគួរតែយកទោសតូចស្រូបចូលទោសធំ មានន័យថាទណ្ឌកម្មដែលធំ។ អ៊ីចឹងយើងឃើញថា សាលក្រមចំនួន២ និងសាលដីកាដែលចូលជាស្ថាពរ មានកម្រិតទណ្ឌកម្មស្មើគ្នា គឺ៦ឆ្នាំ ខ្លួនយល់ឃើញថាគួរស្រូបបញ្ចូលទៅសាលក្រម ឬ សាលដីកាណាមួយ មានន័យថាយកទោស ៦ ឆ្នាំ ស្រូបចូលទោស ៦ ឆ្នាំ។ ក្នុងនាមខ្លួនជាមេធាវីការពារឱ្យទណ្ឌិត [redacted] វិច្ឆិកា សូមសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះ តុលាការកំពូលដែលជាតុលាការសម្រេចចុងក្រោយ សុំមេត្តាស្រូបទោសទណ្ឌកម្ម នៅក្នុងសាលដីកាណាមួយចូលទៅក្នុងសាលដីកាណាមួយ ដើម្បីឱ្យត្រឹមត្រូវតាមគតិនៃច្បាប់ដែលចែងថា ការស្រូបទោសគឺ ពីតូច ទៅធំ។

- ទណ្ឌិត គង់ វិច្ឆិកា បានឆ្លើយថា ខ្លួនសុំស្រូបទោសចូលទៅក្នុងសាលដីកាតែមួយបានហើយ និងសុំស្រូបទោសត្រឹម ៦ឆ្នាំ។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារទណ្ឌិត [redacted] វិច្ឆិកា
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិត [redacted] វិច្ឆិកា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលមេធាវីរបស់ទណ្ឌិត [redacted] វិច្ឆិកា សុំឱ្យតុលាការកំពូលទទួលស្រូបទោសទាំងមូលឱ្យកូនក្តីរបស់ខ្លួន ដោយលើកឡើងថាករណីរបស់កូនក្តីខ្លួន គួរតែតុលាការកំពូលស្រូបបញ្ចូលទោស

Scanned with CamScanner

៦ឆ្នាំ ទៅក្នុងទោសមួយទៀត ៦ឆ្នាំដែរនោះ ទើបជាការសមស្រប។ តុលាការកំពូលពិនិត្យឃើញថា ទណ្ឌិត [redacted]វិច្ឆិកា ត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើស លួចមានស្ថានទម្ងន់ទោសទាំងពីរសាលក្រម ជាបទល្មើសកំពុងកើតមានពេលបច្ចុប្បន្ន។ ដូច្នេះការដែលសាលាឧទ្ធរណ៍បានទទួលឱ្យស្រូបទោស ត្រឹមព្រំដែនអតិបរិមាស្របច្បាប់ លើទោសដែលកំណត់ក្នុងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ គឺទោសត្រូវអនុវត្ត ១០ឆ្នាំ នោះជាការត្រឹមត្រូវហើយ។

៣-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ០៥ "ក្រVII(ធ)" ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ត្រឹមត្រូវនឹងគតិច្បាប់ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- បដិសេធបណ្តឹងសាទុក្ខលេខ ២៥២ ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ទណ្ឌិត [redacted]វិច្ឆិកា។

២- តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ០៥ ក្រVII (ធ) ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទាំងមូល។

*សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។*

Scanned with CamScanner